ភ្នំពេញ , ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៥

**អនុក្រឹត្យ លេខ ៧៩ អនក្រ.បក**

**ស្តីអំពីបុរីសណ្ឋាគារ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពារ រមណីយដ្ឋាន និងរៀបចំតំបន់អង្គរ (អាជ្ញាធរអប្សរា)
- បានឃើញព្រះរាជក្រឹត្យ ស្តីអំពីការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់អនុម័តនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីអំពីការរៀបចំ តំបន់ និងការគ្រប់គ្រងតំបន់សៀមរាបអង្គរ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- គណៈរដ្ឋមន្ត្រីយល់ព្រមផង

**សម្រេច**

**ជំពូកទី ១**

**បុរីសណ្ឋាគារ**

**មាត្រា ១ :** តំបន់ទាំងមូលដែលកំណត់ដោយអក្សរ « ក » ដូចមានកំណត់ក្នុងប្លង់ភ្ជាប់ជាមួយនេះជាកម្មសិទ្ធិ របស់ព្រះរាជាណាចក្រកម្ពុជា នៅទីរួមខេត្តសៀមរាប ហើយត្រូវបានប្រគល់អោយអាជ្ញាធរ «**អប្សរា**» គ្រប់គ្រង និងចាត់ចែងធ្វើជាបុរីសណ្ឋាគារ ។

ទីតាំងនៃបុរីសណ្ឋាគារនេះមានទំហំដីចំនួន ៥៦០ ហិកតា ស្ថិតនៅត្រង់ចំណុចចន្លោះ ចាប់ពី ÷

- ចំណុច១ ខ្សែរយៈបណ្តោយ ៣៧៧៤០០ ខ្សែរយៈទទឹង ១៤៧៨០០០
- ចំណុច២ ខ្សែរយៈបណ្តោយ ៣៧៨១៥០ ខ្សែរយៈទទឹង ១៤៧៩៧០០
- ចំណុច៧ ខ្សែរយៈបណ្តោយ ៣៨១០០០ ខ្សែរយៈទទឹង ១៤៧៩៧២០
- ចំណុច៨ ខ្សែរយៈបណ្តោយ ៣៨១០០០ ខ្សែរយៈទទឹង ១៤៧៨០០០

**មាត្រា ២ :** រាល់ការប្រើប្រាស់ ការប្រកាន់យកជាកម្មសិទ្ធិព្រមទាំងការផ្ទេរសិទ្ធិដីធ្លីទាំងអស់នៅក្នុងតំបន់នេះ ក្រោយពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមានមិនអាចទទួលស្គាល់ ថាត្រឹមត្រូវតាមច្បាប់ឡើយ ។

**មាត្រា ៣ :** អាជ្ញាធរ «**អប្សរា**» ជាអ្នកអភិបាលតំបន់បុរីសណ្ឋាគារនេះ និងទទួលខុសត្រូវលើ ÷

- ការគ្រប់គ្រងចាត់ចែង
- ការថែរក្សាការពារមិនអោយមានការចាប់យកដីធ្លីថ្មីទៀត
- ការរៀបចំ ព្រមទាំងការដាក់អោយធ្វើអាជីវកម្មដីធ្លីគ្រប់បែបយ៉ាង ។

**មាត្រា ៤ :** រាល់បុគ្គលទាំងឡាយដែលបានកាន់កាប់ស្របច្បាប់នូវដីតិច ឬច្រើនក្នុងតំបន់នេះតាំងពីមុនពេល អនុក្រឹត្យនេះចូលជាធរមាន ត្រូវមកផ្តល់ពត៌មានដល់អាជ្ញាធរ «**អប្សរា**» ក្នុងរយៈពេលយ៉ាងយូរ បំផុតមួយឆ្នាំ គិតពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាលើអនុក្រឹត្យនេះ ព្រមទាំងយកមក ជាមួយនូវភ័ស្តុតាងនៃការកាន់កាប់ដីដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ច ។

## ជំពូកទី ២
## តំបន់ដែលត្រូវយកចិត្តទុកដាក់ជាពិសេស

**មាត្រា ៥ :** ស្របតាមព្រះរាជក្រឹត្យ ស្តីពីការកំណត់និងរៀបចំតំបន់សៀមរាបអង្គរ លេខ ០០១ នស ចុះ ថ្ងៃ ២៨ ឧសភា ឆ្នាំ ១៩៩៤ ហើយនិងរបាយការណ៍ភ្ជាប់ ស្តីអំពីតំបន់ទីក្រុងដែលត្រូវថែរក្សា ការពារ ÷

ក–)ត្រង់ចំណុច (៣០–៣១–៣២) ត្រូវបានប្រកាសថា :តំបន់បញ្ញត្តិប្រើប្រាស់ដីក្នុងទទឹង ២៥០ម ម្ខាងៗនៃផ្លូវជាតិលេខ ៦ (មើលប្លង់អក្សរ «ខ ») ។

ខ–)ត្រង់ចំណុច ៣៩ ស្តីអំពីមាត់ច្រាំងស្ទឹងសៀមរាប និងស្ទឹងរលួសដែលត្រូវការពារមាន ទទឹង ៥០០ម ពីច្រាំងម្ខាងៗនៃស្ទឹងសៀមរាប (មើលប្លង់អក្សរ«គ») និងស្ទឹងរលួស ។

គ–)អំពីការគ្រប់គ្រងទេសភាព ហើយនិងសម្បត្តិធម្មជាតិត្រូវបានប្រកាសថា : តំបន់ត្រូវបានការ ពារ (មើលប្លង់អក្សរ«ឃ») ដែលនៅចន្លោះផ្លូវជាតិលេខ ៦ ពីខាងត្បូង និងពីខាងជើង គឺ ត្រង់ព្រំប្រទល់តំបន់ ២ ជាតំបន់ត្រូវការពារនៃឧទ្យានបុរាណវិទ្យា ។

តំបន់ទាំងនេះជាកម្មវត្ថុដែលត្រូវមានវិធានការពិសេសដោយឡែក ។ រាល់ទង្វើដើម្បី បែងចែក ឬរួមបញ្ចូលដីឡូត៍ដែលមានស្រាប់ ព្រមទាំងរាល់គំរោងកែប្រែទ្រង់ទ្រាយទាំងមូល ពាក់ព័ន្ធដល់តំបន់ទាំងនេះ ត្រូវតែដាក់ឆ្លងសុំការអនុញ្ញាតពីអាជ្ញាធរ «**អប្សរា**» ជាមុនសិន ។

**មាត្រា ៦ :** រាល់បទបញ្ញត្តិទាំងឡាយណាផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការនៃស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |


ROYAUME DU CAMBODGE "A.P.S.A.R.A." ETUDE DU PLAN D'URBANISME ET PROJETS PRIORITAIRI
Novembre 1994


381000
1479720
1479700
1479700
H1
H2
Hex
377400
1478000
378650
1478000
381000
1478000
N
N